# ទិប្បដិសារី

(បទកាកគតិ)

នឹកឡើងសែនស្តាយ អាណិតរូបកាយ ធ្លោយធ្លាក់ជ្រោះជ្រាំ
បណ្តោយចិន្តា កាមាដឹកនាំ ជីវិតវេរាំ
ក្នុងល្បែងអបាយ ។

ក្នុងបឋមវ័យ នាទីប្រពៃ សិក្សាមិនណាយ
វិជ្ជាដូចផ្កា មន្តស្នេហ៍ឆើតឆាយ ក្លិនក្រអូបសាយ
ផ្សាយគ្រប់ទិសទី ។

រីឯរូបខ្ញុំ បែរជាចិត្តធំ ពុំគិតសំភី
វង្វេងតម្រា ស្រវាអគ្គី វឹកវរវក់វី
គ្មានយល់ចំលើយ ។

ភ្លូកភ្លឹកភ្លើតភ្លើន ផ្លូវមិនចំរើន ល្ហល្ហេវឥតត្រើយ
ចោលការសិក្សា បែរខ្នងកន្តើយ ត្រាច់ចរក្បៀកកើយ
វិថីទុយិស ។

លុយកាក់ធនធាន ពុកម៉ែប្រទាន ដោយក្តីសង្គ្រោះ
ទុកអោយសិក្សា វិជ្ជាខ្ពង់ខ្ពស់ គ្រាន់បានរានរស់
ក្នុងឈ្មោះឧត្តម ។

ឯខ្ញុំបែរផ្ទាប់ ក្រលាស់ក្រលាប់ ទៅប្រឹងឧបត្ថម្ភ
ផ្លូវល្បែងពាលា ហ៊ឺហាហាក់ហំ ចាយវាយច្រឡំ
ឥតស្តាយស្រណោះ ។

ប្រមូលពួកភឿន ជ្រួលជ្រើមលយលឿន ចូលគ្រប់កៀនកោះ
បនល្បែងស្រីស្រា ស្នេហាហិចហោះ លយឆាយឡេះឡោះ
អស់ហើយទារទៀត ។

បាំងភ្នែកពុកម៉ែ ធ្វើចែចប៉ប្រែ ឬកពាចោលម្សៀត
ម៉ែឪនៅផ្ទះ ខំទូលកណ្តៀត សន្សំឆ្លូកឆ្លៀត
ផ្គត់ផ្គង់កូនរៀន ។

កូនសោតមិនខ្មេះ មិនរកចំនេះ ជំនាញជាស្ពាន

ស៊ីចាយខ្ជះខ្ជាយ    មិនស្តាយធនធាន    ត្រាច់ត្រេកញ៉ាមញៀន
បន បារ ស្រា ស្រី ។

ឆ្នាំមួយឆ្នាំពីរ    ចាប់ប្រាំងមិនស៊ី    ឆ្លងចូលឆ្នាំថ្មី
រៀនដើម្បីរៀន    ពុំមានចេះអ្វី    ថ្នាក់ខ្ពស់ឥតន័យ
មានត្រឹមបរិមាណ ។

ចប់ការសិក្សា    ចូលបំរើការ    តាមខ្សែសន្ទាន
ចេះមិនប្រាកដ    ប្រើការមិនបាន    អ្នកផងរំខាន
ព្រោះមិនចំរើន ។

នឹកស្តាយអតីត    រវល់តែគិត    ភ្លីភ្លើភ្លើតភ្លើន
ភ្លេចភ្លាំងភ្លាត់ផ្លូវ    ផ្ងោតផ្ងោះព្រហើន    អាងធនធានច្រើន
ស្ទួចឡើងចប់ថ្នាក់ ។

ពេលធ្វើការងារ    ទើសទាក់រួញរា    ការមិនប្រត្យក្ស
វិលវល់ចិន្តា    អាប់កេរ្តិ៍យសស័ក្តិ    ខ្មាស់អស់នាង-អ្នក
គេគន់ពេបជ្រាយ ។✍

*(២៦ តុលា ២០០២)*

*ស្វាត សាលឿម*